ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២៨ “ឈ១” ក្រ១១
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ២៩១០
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ២២៥៨
ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ៤០៦៧
ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ២ និង ០០ នាទីរសៀល និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ នៅសាលសវនាការទី១ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក ចៅក្រមប្រឹក្សា
-លោកស្រី ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩១០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] កុសល ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធមុខរបរសិស្ស ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុគីន “រស់” ម្តាយឈ្មោះ [redacted] សុថា “រស់” នៅលីវ ជាអនីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារព្រៃស“ម២” រយៈពេល១ឆ្នាំ ពីបទហិង្សា(វាយគ្នាទៅវិញទៅមកក្នុងសាលា)។ (បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ “PJ”)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៨៣៦ “ខ” ជ.ឃ.ង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២។



Scanned with CamScanner

២.ឈ្មោះ [redacted] គីមស្រៀន ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្សថ្នាក់ទី៩ ទីកន្លែងកំណើតនៅសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះ [redacted] រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] សុខតា "រស់" ម្តាយ ឈ្មោះ [redacted] ស្រីអូន "រស់" ជាអនីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារព្រៃស "ម២" រយៈពេល ០១ឆ្នាំ ពីបទ ហិង្សា(វាយគ្នាទៅវិញទៅមកក្នុងសាលា)។ (បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ "PJ")។

**-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ៤៨៣៧ "ខ".ង.ឃ.ង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២។**

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖** លោកមេធាវី [redacted] នៃការិយាល័យមេធាវី លី និង សហការី ស្ថិតនៅភូមិគ្រឹះលេខ៧០២ ផ្លូវលេខ១១២ (ផ្លូវវត្តចិនពុះភ្លែក) ភូមិបោះអង្កាញ់១ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] គីមស្រៀន ។

៣.ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ភេទប្រុស កើតថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្សថ្នាក់ទី១២ ទីកន្លែងកំណើតនៅ [redacted] ខេត្តក្រចេះ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ២១ ផ្លូវលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វិបុល "រស់" ម្តាយឈ្មោះ [redacted] សុភា "រស់" ជានីតិជន ទោសពីមុនគ្មាន។

**-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ៥២៥៧ "ប".ង.ឃ.ង ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២។**

៤.ឈ្មោះ [redacted] មីនា ហៅ ពេជ្រ ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៤ មុខរបរកម្មករ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅសង្កា [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុកាន "រស់" ម្តាយឈ្មោះ [redacted] គន្ធា "រស់" កម្រិតវប្បធម៌ថ្នាក់ទី៥ ជានីតិជន ទោសពីមុនគ្មាន។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖** លោកមេធាវី [redacted] ជាមេធាវីនៃការិយាល័យមេធាវី ពន្លឺ យុត្តិធម៌ និងជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ។

ជាប់ចោទពីបទ ល្មួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(**ឆក់ទូរស័ព្ទដៃ**) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌល ថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

## អង្គហេតុនៃរឿងមានដូចតទៅះ

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៥ និង២០នាទី មានករណី **ល្មួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ បង្កឡើងដោយជនសង្ស័យចំនួន០៥នាក់ ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] គីមស្រៀន ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ ញ៉ា ភេទប្រុស អាយុប្រហែល១៩ឆ្នាំ, ឈ្មោះ ពេជ្រ ភេទប្រុស អាយុប្រហែល១៩ឆ្នាំ និងឈ្មោះ សីហា ភេទប្រុស អាយុប្រហែល១៩ឆ្នាំ ដែលជនសង្ស័យទាំង០៥នាក់ខាងលើ បានជិះម៉ូតូម៉ូដែល

០៣គ្រឿង ១-ម៉ាកស៊ុយហ្ស៊ុយគីនិច ពណ៌សលាយទឹកក្រូច សេរីឆ្នាំ២០១៩, ២-ម៉ាកហុងដាសេ១២៥ ពណ៌ក្រហមសេរីឆ្នាំ២០២១ និង៣-ម៉ាកស៊ុយហ្ស៊ុយគីនិច ពណ៌សលាយទឹកក្រូច សេរីឆ្នាំ២០១៨។ នៅពេលជនសង្ស័យឈ្មោះ [redacted] គីមសៀន ជិះម៉ូតូឌុបឈ្មោះ [redacted] កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ធ្វើដំណើរតាមផ្លូវលេខ២០០២ ក្នុងទិសដៅពីត្បូងទៅជើង បានឃើញជនសង្ស័យឈ្មោះ ញ៉ា ជិះម៉ូតូឌុបឈ្មោះ ពេជ្រ និងឈ្មោះ សីហា ជិះម៉ូតូម្នាក់ឯងដេញតាមពីក្រោយ ពេលមកដល់ចំណុចទីតាំងកើតហេតុខាងលើ ស្រាប់តែឈ្មោះ ញ៉ា ឌុបឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្ត្រីរងគ្រោះកំពុងអង្គុយលើម៉ូតូ កាន់ទូរស័ព្ទដៃ ហើយឈ្មោះ ពេជ្រ ក៏បានធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះបានសម្រេច ចំណែកឈ្មោះ សីហា ជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ ក្រោយពេលកើតហេតុ ជនរងគ្រោះបានមកប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបែកក្អម ដើម្បីដាក់ពាក្យបណ្តឹង។ លុះនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៥ និង៣០នាទី កម្លាំងការិយាល័យបានស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] គីមសៀន បញ្ជូនមកការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលដើម្បីធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់តែម្តង ។

**-បានឃើញ** របាយការណ៍សំយោគលេខ **២២០/២២ របក** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **២២៥៥ អ.យ.ត** ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៣៨៣០ អ.យ.ត** ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខលេខ **៥១៨៣ "ប" ជ.ជ** ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយ ថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ឈ្មោះ [redacted] **គីមសៀន** បានជិះម៉ូតូឌុបខ្ញុំចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ គោលបំណងទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ ដោយពួកខ្ញុំកំពុងនាំគ្នាជិះម៉ូតូតាមផ្លូវលេខ២០០២ ពីជើងទៅត្បូង ក៏បានឃើញឈ្មោះ **ញ៉ា** ជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ **ពេជ្រ** និងឈ្មោះ **សីហា** ជិះម៉ូតូម៉ាកស៊ុយហ្ស៊ុយគីនិចម្នាក់ឯងជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្ញុំ ហើយឈ្មោះ **ញ៉ា** ក៏បានស្រែកហៅខ្ញុំ រួចខ្ញុំក៏បានបត់ម៉ូតូជិះតាមពីក្រោយឈ្មោះ **ញ៉ា** មកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ស្រាប់តែខ្ញុំឃើញឈ្មោះ **ញ៉ា** ឌុបឈ្មោះ **ពេជ្រ** ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយឈ្មោះ **ពេជ្រ** ជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រី នោះបានសម្រេច រីឯឈ្មោះ **សីហា** ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ ហើយពួកខ្ញុំមិនបានជិះតាមពួកគេទេដោយពួកខ្ញុំជិះម៉ូតូត្រឡប់ទៅហាងកាហ្វេនៅស្ទឹងមានជ័យវិញ។ លុះដល់ម៉ោងប្រហែល ២ រសៀល ថ្ងៃដដែល ឈ្មោះ [redacted] **គីមសៀន** ក៏បានជិះម៉ូតូឌុបខ្ញុំដើម្បីទៅហាងកាហ្វេនៅស្ទឹងមានជ័យ ក៏បានជួបឈ្មោះ **ញ៉ា**, ឈ្មោះ **ពេជ្រ** និងឈ្មោះ **សីហា** ហើយឈ្មោះ [redacted] **គីមស្រៀន** ក៏ចុះពីម៉ូតូរបស់ខ្ញុំ ទៅជិះជាមួយឈ្មោះ **សីហា** វិញ ហើយនាំគ្នាទៅហាងកាហ្វេ។ ប៉ុន្តែខ្ញុំមិនបានទៅជាមួយពួកគេទេ គឺខ្ញុំជិះម៉ូតូតែម្នាក់ឯងត្រឡប់

ក្រោយវិញ ដើម្បីទៅយកទូរស័ព្ទពីមិត្តភក្តិស្រីនៅក្រោយសាលាវិទ្យាល័យជាស៊ីមសាមគ្គីហើយក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ឈ្មោះ [redacted]គីមសៀន ជាអ្នកបើកម៉ូតូម៉ាកនិក NICX។ ទូរស័ព្ទឆក់បាននោះ គឺចែកគ្នាបាន ១០$(ដប់ដុល្លារអាមេរិច) ទៅ ២០$(ម្ភៃដុល្លារអាមេរិច) ក្នុងមួយនាក់។

-ជនជាប់ចោទឈ្មោះ [redacted] **គីមសៀន** ឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង ៣០នាទី ខ្ញុំបានជិះម៉ូតូឌុបឈ្មោះ[redacted]កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ គោលបំណងទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ ដោយពួកខ្ញុំកំពុងនាំគ្នាជិះម៉ូតូតាមផ្លូវលេខ២០០២ ពីជើងទៅត្បូង ក៏បានឃើញឈ្មោះ ញ៉ា ជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ ពេជ្រ និងឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ូគីនិចម្នាក់ឯង ជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្ញុំ ហើយឈ្មោះ ញ៉ា ក៏បានស្រែកហៅឈ្មោះ[redacted] កុសល រួចខ្ញុំក៏បានបត់ម៉ូតូជិះតាមពីក្រោយឈ្មោះ ញ៉ា មកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ស្រាប់តែខ្ញុំឃើញឈ្មោះ ញ៉ា ឌុប ឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយឈ្មោះ ពេជ្រ ជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រីនោះបានសម្រេច រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ ហើយពួកខ្ញុំមិនបានជិះតាមពួកគេទេដោយពួកខ្ញុំជិះម៉ូតូត្រឡប់ទៅហាងកាហ្វេនៅស្ទឹងមានជ័យវិញ។ លុះដល់ម៉ោងប្រហែល ២រសៀល ថ្ងៃដដែល ខ្ញុំក៏បានជិះម៉ូតូឌុបឈ្មោះ [redacted] កុសល ដើម្បីទៅហាងកាហ្វេនៅស្ទឹងមានជ័យ ក៏បានជួបឈ្មោះ ញ៉ា, ឈ្មោះ ពេជ្រ និងឈ្មោះ សីហា ហើយខ្ញុំក៏ចុះពីម៉ូតូរបស់ឈ្មោះ [redacted] កុសល ទៅជិះជាមួយឈ្មោះ សីហា វិញ ហើយនាំគ្នាទៅហាងកាហ្វេ។ ប៉ុន្តែឈ្មោះ[redacted]កុសល មិនបានទៅជាមួយពួកគេទេ គឺខ្ញុំជិះម៉ូតូតែម្នាក់ឯងត្រឡប់ក្រោយវិញ ដើម្បីទៅយកទូរស័ព្ទពីមិត្តភក្តិស្រីនៅក្រោយសាលាវិទ្យាល័យជាស៊ីមសាមគ្គី បាត់ទៅ។ ពេលទៅដល់ហាងកាហ្វេឈ្មោះ ញ៉ា, ឈ្មោះ សីហា និងឈ្មោះ ពេជ្រ ក៏នាំគ្នាជិះម៉ូតូចេញទៅបាត់ ហើយក្រោយមកខ្ញុំក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន រួមទាំងវត្ថុតាងជាម៉ូតូរបស់ខ្ញុំតែម្តង។ ចំពោះសកម្មភាពឆក់នេះគឺមានការឯកភាពគ្នាក្នុងការធ្វើសកម្មភាព ហើយទូរស័ព្ទឆក់បាននោះ គឺចែកគ្នាបាន ១០$(ដប់ដុល្លារអាមេរិច) ទៅ ២០$ (ម្ភៃដុល្លារអាមេរិច) ក្នុងមួយនាក់។

-ជនជាប់ចោទឈ្មោះ [redacted]**មីនា** ហៅ **ពេជ្រ** បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ឈ្មោះ [redacted]គីមសៀន បានជិះម៉ូតូឌុបឈ្មោះ[redacted]កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ ពេលនោះពួកវាក៏បានជួបឈ្មោះ[redacted]បញ្ញា ហៅ ញ៉ា កំពុងជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបខ្ញុំ នៅម្តុំស្ទឹងមានជ័យ, ឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ូយគីនិចម្នាក់ឯង ជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្ញុំ ហើយឈ្មោះ វ៉ន បញ្ញា ហៅ ញ៉ា ក៏បានស្រែកហៅឈ្មោះ[redacted]កុសល ឮដូច្នេះពួកវាក៏បានបត់ម៉ូតូមកតាមពីក្រោយខ្ញុំ ពេលមកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ពេលនោះឈ្មោះ[redacted] បញ្ញា ហៅ ញ៉ា កំពុងឌុបខ្ញុំ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយខ្ញុំជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រីនោះបានសម្រេច។ រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ បន្ទាប់ពីខ្ញុំបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេចហើយ ក៏ជិះម៉ូតូគេចខ្លួនយកទូរស័ព្ទដៃដែលឆក់បាននោះទៅលក់នៅម្តុំផ្សារពោធិ៍ចិនតុង បានប្រាក់ចំនួន២២០ដុល្លារអាមេរិក រួចក៏ជិះម៉ូតូទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ។ ចំណែកបក្ខពួកខ្ញុំជិះម៉ូតូគេចខ្លួនបាត់ដែរ។ លុះនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០២២ វេលាម៉ោង១២ និង៣០នាទី ខ្ញុំកំពុងអង្គុយលេងនៅវត្តសំបួរមាស សង្កាត់ដង្កោ ក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ បក្ខពួករបស់ខ្ញុំ ០៣ម៉ូតូ គឺឈ្មោះ សីហា ឈ្មោះ[redacted] កុសល និងឈ្មោះ[redacted] បញ្ញា។

-ជនជាប់ចោទឈ្មោះ[redacted]បញ្ញា ហៅ ញ៉ា បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៣ និង៣០នាទី ឈ្មោះ [redacted] គីមសៀន បានជិះម៉ូតូឌុបឈ្មោះ[redacted]កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ



Scanned with CamScanner

២០០២ ពេលនោះពួកវាក៏បានជួប ខ្ញុំកំពុងជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ [redacted] មីនា ហៅ ពេជ្រ នៅម្តុំស្ទឹងមានជ័យ, ឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ូឃីនិចម្នាក់ឯង ជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្ញុំ ហើយខ្ញុំក៏បានស្រែកហៅឈ្មោះ [redacted] កុសល ឮដូច្នេះពួកវាក៏បានបត់ម៉ូតូមកតាមពីក្រោយខ្ញុំ ពេលមកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ពេលនោះខ្ញុំកំពុងឌុបឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយខ្ញុំជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃម៉ាកOPPO ពីមនុស្សស្រីនោះបានសម្រេច។ រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ បន្ទាប់ពីខ្ញុំបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេចហើយ ក៏ជិះម៉ូតូគេចខ្លួនយកទូរស័ព្ទដៃដែលឆក់បាននោះទៅលក់នៅម្តុំផ្សារពោធិ៍ចិនតុង បានប្រាក់ចំនួន២២០ដុល្លារអាមេរិក រួចក៏ជិះម៉ូតូទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ។ ចំណែកបក្ខពួកខ្ញុំជិះម៉ូតូគេចខ្លួនបាត់ដែរ។ លុះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៦ និង០០នាទី ខ្ញុំក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ទូរស័ព្ទឆក់បាន គឺលក់បាន ២៤០$(ពីររយសែសិបដុល្លារអាមេរិច) ហើយចែកបាន៤០$(សែសិបដុល្លារអាមេរិច) ក្នុងមួយនាក់។

-ក្រឡាបញ្ជីអានកំណត់ហេតុវត្ថុចាប់យក "១" របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញលេខ ១១៥៨ រ.វ.ត ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២៖ **សម្ភារៈរបស់ឈ្មោះ [redacted] កុសល រួមមាន៖** ម៉ូតូ SUZUKI NEX ពណ៌ស-ទឹកក្រូច ផ្លាកលេខ ភ្នំពេញ 1HP-8206 ចំនួន១(មួយគ្រឿង) (មិនប្រក្រតី) និងទូរស័ព្ទម៉ាក IPHONE ពណ៌ស ចំនួន ១(មួយ)គ្រឿង (មិនដំណើរការ) ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្រពណ៌សចំនួន១(មួយ) ដោយមានស្នាមម្រាមដៃជនសង្ស័យឈ្មោះ [redacted] គឹមស្រៀង និងមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តធម៌ និងក្រឡាបញ្ជី។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖** ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថាជនជាប់ចោទ១.ឈ្មោះ [redacted] កុសល ២.ឈ្មោះ [redacted] គឹមស្រៀន ៣.ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ៤.ឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានសារភាពថាបក្ខពួកខ្លួនពិតជាបានឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន។ អំពើនេះគឺជាបទល្មើសព្រហ្មទណ្ឌបទ **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា (ឆក់ទូរស័ព្ទដៃ)** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំលោកចៅក្រមសម្រេចសេចក្តីតាមច្បាប់។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ ៖**

-លោកមេធាវី [redacted] សន្និដ្ឋានថា៖ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថា កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានសារភាពខ្លួនពិតជាបានឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន ក៏ប៉ុន្តែកូនក្តីរបស់ខ្ញុំបាទទាំងពីរនាក់ទើបតែធ្លាប់ប្រព្រឹត្ត



Scanned with CamScanner

អាយុក្តាយជានីតិជនថ្មីៗ ដែលមិនទាន់យល់ច្បាស់ពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ដូច្នេះ ខ្ញុំសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្ញុំបាទ។

-លោកមេធាវី [redacted] លោកមេធាវី [redacted] សន្និដ្ឋានថា៖ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថា កូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] កុសល ឈ្មោះ [redacted] គីមស្រៀន បានសារភាពខ្លួនពិតជាបានចូលរួមសកម្មភាព ឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន ក៏ប៉ុន្តែកូនក្តីរបស់ខ្ញុំបាទទាំងពីរនាក់ជាអនីតិជន និងជាសិស្សកំពុងសិក្សានៅឡើយ ដែលមិនទាន់យល់ច្បាស់ពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ដូច្នេះ ខ្ញុំសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្ញុំបាទ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ៖**

ជនជាប់ចោទឈ្មោះ [redacted] កុសល សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted] គីមស្រៀន សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

ជនជាប់ចោទឈ្មោះ [redacted] មីនា ហៅ ពេជ្រ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរ និងសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ២៩១០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ មកជំនុំជម្រះដែលមានដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥១៨៣ "ប" ដ.ង ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទ ១.ឈ្មោះ [redacted] កុសល ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ ២.ឈ្មោះ [redacted] គីមស្រៀន ភេទប្រុស អាយុ ១៧ឆ្នាំ ៣.ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ភេទប្រុស អាយុ ១៨ឆ្នាំ ៤.ឈ្មោះ [redacted] មីនា ហៅ ពេជ្រ ភេទប្រុស អាយុ ១៨ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌល ថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយ ថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ឈ្មោះ [redacted] គីមសៀន បានជិះម៉ូតូឌុបខ្លួនចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ គោលបំណងទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ ដោយពួកខ្លួនកំពុងនាំគ្នាជិះម៉ូតូតាមផ្លូវលេខ២០០២ ពីជើងទៅត្បូង ក៏បានឃើញឈ្មោះ ញ៉ា ជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ ពេជ្រ និងឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ូគីនិចម្នាក់ឯងជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្លួន ហើយឈ្មោះ ញ៉ា ក៏បានស្រែកហៅខ្លួន រួចខ្លួនក៏បានបត់ម៉ូតូជិះតាមពីក្រោយឈ្មោះ ញ៉ា មកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអ៊ែនឃែរ ស្រាប់តែខ្លួនឃើញឈ្មោះ ញ៉ា ឌុបឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយឈ្មោះ ពេជ្រ ជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រី នោះបានសម្រេច រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ ហើយពួកខ្លួនមិនបានជិះតាមពួកគេទេដោយពួកខ្លួនជិះម៉ូតូត្រឡប់ទៅហាងកាហ្វេនៅស្ទឹងមានជ័យវិញ។ លុះដល់ម៉ោងប្រហែល ៥រសៀល ថ្ងៃដដែល ឈ្មោះ [redacted] គីមសៀន ក៏បានជិះម៉ូតូឌុបខ្លួនដើម្បីទៅហាងកាហ្វេនៅស្ទឹងមានជ័យ ក៏បានជួបឈ្មោះ ញ៉ា, ឈ្មោះ ពេជ្រ និងឈ្មោះ សីហា ហើយឈ្មោះ [redacted] គីមស្រៀន ក៏ចុះពីម៉ូតូរបស់ខ្លួន ទៅជិះជាមួយឈ្មោះ សីហា វិញ ហើយនាំគ្នាទៅហាងហ្វេ។ ប៉ុន្តែខ្លួនមិនបានទៅជាមួយពួកគេទេ គឺខ្លួនជិះម៉ូតូតែម្នាក់ឯងត្រឡប់ក្រោយវិញ ដើម្បីទៅយកទូរស័ព្ទពីមិត្តភក្តិស្រីនៅក្រោយសាលាវិទ្យាល័យជាស៊ីមសាមគ្គីហើយក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ឈ្មោះ [redacted] គីមសៀន ជាអ្នកបើកម៉ូតូម៉ាកនិក NICX។ ទូរស័ព្ទឆក់បាននោះ គឺចែកគ្នាបាន ១០$(ដប់ដុល្លារអាមេរិច) ទៅ ២០$(ម្ភៃដុល្លារអាមេរិច) ក្នុងមួយនាក់។

៣-ជនជាប់ចោទឈ្មោះ [redacted] គីមសៀន ឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ខ្លួនបានជិះម៉ូតូឌុបឈ្មោះ គង់ កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ គោលបំណងទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ ដោយពួកខ្លួនកំពុងនាំគ្នាជិះម៉ូតូតាមផ្លូវលេខ២០០២ ពីជើងទៅត្បូង ក៏បានឃើញឈ្មោះ ញ៉ា ជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ ពេជ្រ និងឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ូគីនិចម្នាក់ឯងជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្លួន ហើយឈ្មោះ ញ៉ា ក៏បានស្រែកហៅឈ្មោះ [redacted] កុសល រួចខ្លួនក៏បានបត់ម៉ូតូជិះតាមពីក្រោយឈ្មោះ ញ៉ា មកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអ៊ែនឃែរ ស្រាប់តែខ្លួនឃើញឈ្មោះ ញ៉ា ឌុប ឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយឈ្មោះ ពេជ្រ ជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រីនោះបានសម្រេច រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ ហើយពួកខ្លួនមិនបានជិះតាមពួកគេទេដោយពួកខ្លួនជិះម៉ូតូត្រឡប់ទៅហាងកាហ្វេនៅស្ទឹងមានជ័យវិញ។ លុះដល់ម៉ោងប្រហែល៥រសៀល ថ្ងៃដដែល ខ្លួនក៏បានជិះម៉ូតូឌុបឈ្មោះ [redacted] កុសល ដើម្បីទៅហាងកាហ្វេនៅស្ទឹងមានជ័យ ក៏បានជួបឈ្មោះ ញ៉ា, ឈ្មោះ ពេជ្រ និងឈ្មោះ សីហា ហើយខ្លួនក៏ចុះពីម៉ូតូរបស់ឈ្មោះ [redacted] កុសល ទៅជិះជាមួយឈ្មោះសីហា វិញ ហើយនាំគ្នាទៅហាងកាហ្វេ។ ប៉ុន្តែឈ្មោះ [redacted] កុសល មិនបានទៅជាមួយពួកគេទេ គឺខ្លួនជិះម៉ូតូតែម្នាក់ឯងត្រឡប់ក្រោយវិញ ដើម្បីទៅយកទូរស័ព្ទពីមិត្តភក្តិស្រីនៅក្រោយសាលាវិទ្យាល័យជាស៊ីមសាមគ្គី បាត់ទៅ។ ពេលទៅដល់ហាងកាហ្វេឈ្មោះ ញ៉ា, ឈ្មោះ សីហា និងឈ្មោះ ពេជ្រ ក៏នាំគ្នាជិះម៉ូតូចេញទៅបាត់ ហើយក្រោយមកខ្លួនក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន រួមទាំងវត្ថុតាងជាម៉ូតូរបស់ខ្លួនតែម្តង។ ចំពោះសកម្មភាពឆក់នេះគឺមានការឯកភាពគ្នាក្នុងការធ្វើសកម្មភាព ហើយទូរស័ព្ទឆក់បាននោះ គឺចែកគ្នាបាន ១០$(ដប់ដុល្លារអាមេរិច) ទៅ ២០$(ម្ភៃដុល្លារអាមេរិច) ក្នុងមួយនាក់។

៤-ជនជាប់ចោទឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ឈ្មោះ [redacted] គីមសៀន បានជិះម៉ូតូឌុបឈ្មោះ [redacted] កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ ពេលនោះពួកវាក៏បានជួបឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា កំពុងជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុ

បខ្លួន នៅម្តុំស្ទឹងមានជ័យ, ឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ីយគីនិចម្នាក់ឯង ជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្លួន ហើយឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ក៏បានស្រែកហៅឈ្មោះ [redacted] កុសល ឲ្យដូច្នេះពួកវាក៏បានបត់ម៉ូតូមកតាមពីក្រោយខ្លួន ពេលមកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ពេលនោះឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា កំពុងឌុបខ្លួន ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយខ្លួនជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីមនុស្សស្រីនោះបានសម្រេច។ រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ បន្ទាប់ពីខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេចហើយ ក៏ជិះម៉ូតូគេចខ្លួនយកទូរស័ព្ទដៃដែលឆក់បាននោះទៅលក់នៅម្តុំផ្សារពោធិ៍ចិនតុង បានប្រាក់ចំនួន២២០ដុល្លារអាមេរិក រួចក៏ជិះម៉ូតូទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ។ ចំណែកបក្ខពួកខ្លួនជិះម៉ូតូគេចខ្លួនបាត់ដែរ។ លុះនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០២២ វេលាម៉ោង១២ និង៣០នាទី ខ្លួនកំពុងអង្គុយលេងនៅវត្តសំប្តូរមាស សង្កាត់ដង្កោ ក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។

៥-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣ និង៣០នាទី ឈ្មោះ [redacted] គីមសៀន បានជិះម៉ូតូឌុបឈ្មោះ [redacted] កុសល ចេញពីហូបអាហារនៅផ្សារផ្លូវលេខ២០០២ ពេលនោះពួកវាក៏បានជួប ខ្លួនកំពុងជិះម៉ូតូម៉ាកហុងដាសេ១២៥ ឌុបឈ្មោះ [redacted] មីនា ហៅ ពេជ្រ នៅម្តុំស្ទឹងមានជ័យ, ឈ្មោះ សីហា ជិះម៉ូតូម៉ាកស៊ុយហ្ស៊ីយគីនិចម្នាក់ឯង ជិះបញ្ច្រាស់ទិសគ្នាជាមួយពួកខ្លួន ហើយខ្លួនក៏បានស្រែកហៅឈ្មោះ [redacted] កុសល ឲ្យដូច្នេះពួកវាក៏បានបត់ម៉ូតូមកតាមពីក្រោយខ្លួន ពេលមកដល់ចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ពេលនោះខ្លួនកំពុងឌុបឈ្មោះ ពេជ្រ ជិះម៉ូតូចូលទៅជិតស្រីម្នាក់កំពុងអង្គុយលើម៉ូតូ ហើយខ្លួនជាអ្នកធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃម៉ាកOPPO ពីមនុស្សស្រីនោះបានសម្រេច។ រីឯឈ្មោះ សីហា ជាអ្នកជិះម៉ូតូបិទគូថពីក្រោយនាំគ្នាជិះម៉ូតូគេចខ្លួនបាត់។ បន្ទាប់ពីខ្លួនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេចហើយ ក៏ជិះម៉ូតូគេចខ្លួនយកទូរស័ព្ទដៃដែលឆក់បាននោះទៅលក់នៅម្តុំផ្សារពោធិ៍ចិនតុង បានប្រាក់ចំនួន២២០ដុល្លារអាមេរិក រួចក៏ជិះម៉ូតូទៅផឹកកាហ្វេនៅម្តុំស្ទឹងមានជ័យ។ ចំណែកបក្ខពួកខ្លួនជិះម៉ូតូគេចខ្លួនបាត់ដែរ។ លុះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង១៦ និង០០នាទី ខ្លួនក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ទូរស័ព្ទឆក់បាន គឺលក់បាន ២៤០$(ពីររយសែសិបដុល្លារអាមេរិច) ហើយចែកបាន៤០$(សែសិបដុល្លារអាមេរិច) ក្នុងម្នាក់។

៦-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក(១) របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ លេខ ១១៥៨ រ.វ.ត ចុះថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០២២៖

ក.សម្ភារះរបស់ឈ្មោះ [redacted] កុសល រួមមាន៖

-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ផ្លាកលេខ ភ្នំពេញ 1HP-៨២០៦ ចំនួន១(មួយ)គ្រឿង (មិនប្រក្រតី)។

-ទូរស័ព្ទម៉ាក IPHONE ពណ៌ស ចំនួន១(មួយ)គ្រឿង (មិនដំណើរការ)។

ខ.សម្ភារះរបស់ឈ្មោះ [redacted] គីមស្រៀន រួមមាន៖

-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ 1JM-៧១៣៧ ចំនួន១(មួយ)គ្រឿង (មិនប្រក្រតី)។

-ទូរស័ព្ទម៉ាក IPHONE ពណ៌លឿង ចំនួន១(មួយ)គ្រឿង (មិនដំណើរការ)។



Scanned with CamScanner

៧-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថាជនជាប់ចោទ១.ឈ្មោះ [redacted] កុសល ២.ឈ្មោះ [redacted] គីមស្រៀន ៣.ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ៤.ឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានសារភាពថាបក្ខពួកខ្លួនពិតជាបានឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន។ អំពើនេះគឺជាបទល្មើសព្រហ្មទណ្ឌបទ **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ)** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងស្នើសុំលោកចៅក្រមសម្រេចសេចក្តីតាមច្បាប់ គប្បីតុលាការពិចារណា។

**៨-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ ៖**

-លោកមេធាវី [redacted] សន្និដ្ឋានថា៖ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានសារភាពខ្លួនពិតជាបានឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន ក៏ប៉ុន្តែកូនក្តីរបស់ខ្លួនទាំងពីរនាក់ទើបតែចូលដល់អាយុក្លាយជានីតិជនថ្មីៗ ដែលមិនទាន់យល់ច្បាស់ពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ដូច្នេះ ខ្លួនសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន។

-លោកមេធាវី [redacted] លោកមេធាវី [redacted] សន្និដ្ឋានថា៖ ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការ និងបានស្តាប់កំណត់ហេតុនានាក្នុងសំណុំរឿង ឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] កុសល ឈ្មោះ [redacted] គីមស្រៀន បានសារភាពខ្លួនបពិតជាបានចូលរួមសកម្មភាព ឆក់ទូរស័ព្ទម៉ាកOPPO ពីមនុស្សស្រីម្នាក់ដែលអង្គុយលើម៉ូតូនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ពិតប្រាកដមែន ក៏ប៉ុន្តែកូនក្តីរបស់ខ្លួនទាំងពីរនាក់ជាអនីតិជន និងជាសិស្សកំពុងសិក្សានៅឡើយ ដែលមិនទាន់យល់ច្បាស់ពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ដូច្នេះ ខ្លួនសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន។

៩-ជនជាប់ចោទឈ្មោះ [redacted] កុសល ឈ្មោះ [redacted] គីមស្រៀន ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ មានសំដីចុងក្រោយ ដែលសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា ។

១០-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាល របាយការណ៍របស់សមត្ថកិច្ច សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សំណូមពរ និង សំដីចុងក្រោយរបស់ជនជាប់ចោទ ភស្តុតាងនានាក្នុងសំណុំរឿង ឃើញថាអំពើរបស់ជាប់ចោទឈ្មោះ [redacted] កុសល ឈ្មោះ

[redacted] គីមស្រៀន ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ ពិតជាមានចេតនាឆក់យកទូរស័ព្ទរបស់ជនរងគ្រោះប្រាកដមែន ដែលអំពើនេះគឺជាបទល្មើស លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា (ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១១-ជនជាប់ចោទឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] គីមស្រៀន ជាអនីតិជន និងជាជនមិនទាន់មានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់។

១២-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ ជានីតិជន និងជាជនមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់។

១៣-អំពើដែលជនជាប់ចោទ ឈ្មោះ [redacted] កុសល ឈ្មោះ អាន គីមស្រៀន ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះនិង សណ្តាប់ធ្នាប់របៀបរៀបរយសង្គមធ្ងន់ធ្ងរ។

១៤-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] កុសល ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ និងឈ្មោះ [redacted] គីមស្រៀន ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ និងពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

១៥-មានពិរុទ្ធិភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] មីនា ហៅ ពេជ្រ ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃៃរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១៦-ជនជាប់ចោទឈ្មោះ [redacted] កុសល ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ ជាអនីតិជន និងទើបតែជាសិស្សថ្នាក់ទី១២ ដែលមិនទាន់មានការពិចារណាពេញលេញអំពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់នៅឡើយ ហើយអាកប្បកិរិយារបស់ជនជាប់ចោទឈ្មោះ [redacted] កុសល មានការសោកស្ដាយ និងដឹងកំហុសរបស់ខ្លួនផងដែរ មិនតែប៉ុណ្ណោះទោសដែលតុលាការអាចប្រកាសក្នុងបទល្មើសនេះ គឺពី ១(ប្រាំ)ឆ្នាំ និង ៦(ប្រាំមួយ)ខែ ទៅ ៥(ប្រាំ) ឆ្នាំ ប៉ុណ្ណោះ ដូច្នេះគប្បីតុលាការផ្តន្ទាសទោសជនជាប់ចោទដាក់ពន្ធនាគារតែទោសនេះត្រូវព្យួរមួយផ្នែក តាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

១៧-ជនជាប់ចោទឈ្មោះ [redacted] គីមស្រៀន ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ ជាសិស្សថ្នាក់ទី៩ ដែលមិនទាន់មានការពិចារណាពេញលេញអំពីអំពើរបស់ខ្លួនតាមផ្លូវច្បាប់នៅឡើយ ហើយអាកប្បកិរិយារបស់



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] គីមស្រៀន មានការសោកស្ដាយ និងដឹងកំហុសរបស់ខ្លួនផងដែរ មិនតែប៉ុណ្ណោះទោសដែលតុលាការអាចប្រកាសក្នុងបទល្មើសនេះ គឺពី ១(ប្រាំ)ឆ្នាំ និង ៦(ប្រាំមួយ)ខែ ទៅ ៥(ប្រាំ)ឆ្នាំ ប៉ុណ្ណោះ ដូច្នេះ គប្បីតុលាការផ្ដន្ទាសទោសជនជាប់ចោទដាក់ពន្ធនាគារតែទោសនេះត្រូវព្យួរមួយផ្នែក តាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

**១៨- វត្ថុចាប់យក៖**

-ម៉ូតូម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ផ្លាកលេខ ភ្នំពេញ 1HP-៨២០៦ ចំនួន១(មួយ)គ្រឿង (មិនប្រក្រតី) និងម៉ូតូម៉ាក SUZUKI NEX ពណ៌ស ផ្លាកលេខ ភ្នំពេញ 1JM-៧១៣៧ ចំនួន១(មួយ)គ្រឿង (មិនប្រក្រតី) ត្រូវបានប្រគល់ឱ្យម្ចាស់ដើមតាមដីកាសម្រេចលេខ **១៩៣ អ.យ.ត** ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ រួចហើយ ដូច្នេះ តុលាការមិនធ្វើការសម្រេចទៀតទេ។

-ទូរស័ព្ទម៉ាក IPHONE ពណ៌ស ចំនួន១(មួយ)គ្រឿង (មិនដំណើរការ) និងទូរស័ព្ទម៉ាក IPHONE ពណ៌លឿង ចំនួន១(មួយ)គ្រឿង (មិនដំណើរការ) គប្បីរឹបអូសជាសម្បត្តិរដ្ឋ តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

**១-<u>ផ្ដន្ទាទោស</u>៖**

**១.១** ឈ្មោះ [redacted] កុសល ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ជនជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ និង៦(ប្រាំមួយ)ខែ** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារ **០១(មួយ)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ)**ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា**៣៥៧** និងមាត្រា**១៦០** និងមាត្រា**១០៨** នៃក្រមព្រហ្មទណ្ឌ។

**១.២** ឈ្មោះ [redacted] **គីមស្រៀន** ភេទប្រុស កើតថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ សញ្ជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ និង៦(ប្រាំមួយ)ខែ** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារ **០១(មួយ)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរ** ពីបទ**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ)**ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា**៣៥៧** និងមាត្រា**១៦០** និងមាត្រា**១០៨** នៃក្រមព្រហ្មទណ្ឌ។

**១.៣** ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់ **៣(បី)ឆ្នាំ** ពីបទ**លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ)**ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១.៤ ឈ្មោះ [redacted] មីនា ហៅ ពេជ្រ ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ទោសពន្ធនាគារកំណត់ ៣(បី)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា(ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចទល់មុខមជ្ឈមណ្ឌលថែទាំរថយន្តអែនឃែរ ផ្ទះលេខ២៦៧ ផ្លូវលេខ២០០២ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-<u>វត្ថុចាប់យក</u>៖

ទូរស័ព្ទម៉ាក IPHONE ពណ៌ស ចំនួន១(មួយ)គ្រឿង (មិនដំណើរការ) និងទូរស័ព្ទម៉ាក IPHONE ពណ៌លឿង ចំនួន១(មួយ)គ្រឿង (មិនដំណើរការ) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ តាមបញ្ញត្តិមាត្រា៦២ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ និងប្រកាសសាលក្រមជាអសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ ១.ឈ្មោះ [redacted]សុល ២.ឈ្មោះ [redacted] គីមស្រៀន ៣.ឈ្មោះ [redacted] បញ្ញា ហៅ ញ៉ា ៤.ឈ្មោះ [redacted] មីនា ហៅ ពេជ្រ ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១១រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]